ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង
## រវាង
## ក្រុមហ៊ុនឌូហ៊ីស្ត (ខេមបូឌា) ខូអិលធីឌី
## និង
## តំណាងប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋាន
## នៃក្រុមហ៊ុនឌូហ៊ីស្ត (ខេមបូឌា) ខូអិលធីឌី

## ស្តីអំពីការបើកប្រាក់ឧបត្ថម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ០១រសៀល នៅក្នុងរោងចក្រ ឌូហ៊ីស្ត (ខេមបូឌា) មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិត សហជីពមូលដ្ឋាន ដែលមានភាពជាតំណាងបំផុតប្រចាំរោងចក្រ ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅតែកង្វះខាតវត្ថុធាតុដើម និងការរីករាលដាលនៃជម្ងឺកូវីដ ១៩ ដែលជាកត្តាចម្បងដែលធ្វើឲ្យទីផ្សារនៅអឺរ៉ុប អាមេរិក កាណាដាក៏ដូចជាទីផ្សារពិភពលោកមានការធ្លាក់ចុះ និងមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ អ្នកបញ្ជាទិញបានផ្អាក និងបញ្ឈប់ការបញ្ជាទិញ និងមិនអនុញ្ញាតិឲ្យមានការនាំទំនិញចេញផងដែរ។

ទាំងនេះជាមូលហេតុដែលនាំឲ្យក្រុមហ៊ុនឌូហ៊ីស្ត (ខេមបូឌា) ខូអិលធីឌី ពុំមានលទ្ធភាពក្នុងការផ្តល់ការងារជូនកម្មករនិយោជិតមួយចំនួនក្នុងមួយរយៈពេលនេះ។

ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងារ របស់កម្មករនិយោជិត ចំនួន ១៣៤ (ស្រី ៨២ នាក់) ជាលើកទី៨ ដែលមានរយៈពេលគិតចាប់ពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២០ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ កម្មករនិយោជិតនឹងទទួលបានប្រាក់ឧបត្ថម្ភតាមសេចក្តីណែនាំលេខ ០២៥/២០ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ ដែលនឹងត្រូវបានផ្តល់ជូនតាមរយៈប្រព័ន្ធធនាគារដែលបាននឹងកំពុងអនុវត្ត។

យើងខ្ញុំទាំងអស់គ្នាយល់ព្រមក្នុងការបើកប្រាក់ឈ្នួលប្រចាំខែមួយខែម្តងជំនួសឲ្យការបើកប្រាក់ឈ្នួលពីរដងក្នុងមួយខែក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារនេះ។

ឌូហ៊ីស្ត (ខេមបូឌា)
Dewhirst (Cambodia) Co., Ltd

អង្គប្រជុំបានបញ្ចប់វេលាម៉ោង១១ និង ៣០នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងខាង មានភាពស្និទ្ធស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួលខុសត្រូវ និងសហការគ្នាយ៉ាងល្អ។

ថ្ងៃសុក្រ ១១ កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០២០

**តំណាងកម្មករនិយោជិត និងតំណាងសហជីព** **តំណាងក្រុមហ៊ុន**

ឈួក គង់ហាក ខាត់ ប៊ុនណា ផៃ គ្រា

ស៊ុយ កុមារកាញ្ច ណែម សោភ័ណ្ឌ ក្រុំ ថារី

សំ សាម៉ុល អន បូរ៉ៃ ស៊ាត ណារិន ចាប ថៃ

វៃហ គីស៊ា រ័ត្ន សំណាង ខុន សុខហេង សាវឿន ណារី

ពៅ ពិសី សេង ធន សុខ គីមហេង គ្រី សៀកឡាង រុងរឿង វិច្ឆិន

ឃន វិតទេត ឈឿន សុគ៌ុត ឈេង សុបិន្តប៉ុន ម៉ាន់ រ៉ាមី ម៉េង ហួរ